គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
លេខ..........០៧០ សសរ/.គ.ជ.វ.វ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី.០៧..ខែ.ឧសភា...ឆ្នាំ២០០៧

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងមន្ត្រីនៃក្រុមគាំទ្រកម្មវិធី

៚៚៚✿៛៛៛

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន
## គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៥៥ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៦ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ ១៦/អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្ដីសំរេចលេខ ០៩ សសរ/គ.ជ.វ.វ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្ដីពីការបង្កើតក្រុមគាំទ្រកម្មវិធីនៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញឯកសារគំរោងគាំទ្រកិច្ចអភិវឌ្ឍន៍ប្រជាធិបតេយ្យតាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ ដែលបានចុះហត្ថលេខា នាថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៧
- ផ្អែកលើលក្ខណៈចាំបាច់ការងារ

# សម្រេច

**ប្រការ១:-**

តែងតាំងមន្ត្រីមួយចំនួនក្នុងក្រុមគាំទ្រកម្មវិធី នៃគណៈកម្មាធិការជាតិដឹកនាំកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ (គ.ជ.វ.វ) :

- លោក **គៀង សត្ថាវុធ** ជាជំនួយការនាយកក្រុមគាំទ្រកម្មវិធី
- លោក **ម៉ុង សេរី** ជាមន្ត្រីទទួលបន្ទុកកិច្ចការទូទៅខាងហិរញ្ញវត្ថុនៃក្រុមគាំទ្រកម្មវិធី
- លោក **ស៊ុន ស៊ីដេត** ជាមន្ត្រីលទ្ធកម្មក្នុងផ្នែករដ្ឋបាលនៃក្រុមគាំទ្រកម្មវិធី

**ប្រការ២:-**

ក្រសួង និងស្ថាប័នជាសមាជិក គ.ជ.វ.វ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធចំណុះ ក្រសួងមហាផ្ទៃ នាយកនិងនាយករងក្រុមគាំទ្រកម្មវិធី ប្រធានផ្នែកទាំង៤ នៃក្រុមគាំទ្រកម្មវិធី ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះ ។

**ប្រការ៣:-**

សេចក្តីសម្រេចនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រធាន គ.ជ.វ.វ**

**កន្លែងទទួល :**

- ក្រសួងសមាជិក គ.ជ.វ.វ
- គណៈកម្មការប្រតិបត្តិគ្រប់ខេត្ត ក្រុង
- ដៃគូអភិវឌ្ឍន៍ UNDP DFID SIDA
- គម្រោង PSDD
  (ដើម្បីជូនជ្រាប)
- សាមីខ្លួន
  (ដើម្បីអនុវត្ត)
- ឯកសារ